ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២៣

ពី៖ អង្គការសង្គមស៊ីវិលខ្មែរនៅទូទាំងពិភពលោក
ជូនចំពោះ៖ មេដឹកនាំពិភពលោក

កម្មវត្ថុ៖ រដ្ឋាភិបាលបរទេស ត្រូវកុំទទួលស្គាល់លទ្ធផលបោះឆ្នោតជាតិក្លែងក្លាយនៅកម្ពុជា

ឯកឧត្តម និងលោកជំទាវ៖

សហគមន៍ខ្មែរនៅទូទាំងពិភពលោក មកជួបជុំគ្នាថ្ងៃនេះ ក្នុងវេទិកាជួបផ្ទាល់ និងតាមអនឡាញ នៅទីក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា ក្រោមប្រធានបទ "វេទិកាពលរដ្ឋខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ៖ ពីពេលនេះទៅមុខ គោលដៅយើងត្រូវធ្វើអ្វីទៀត**?**"។ ពលរដ្ឋសហគមន៍ បានប្ដេជ្ញាចិត្តជាថ្មី ដើម្បីបុព្វហេតុតស៊ូមតិសម្រាប់កម្ពុជា អមដោយ "ការតាំងចិត្តតស៊ូមតិរបស់សហគមន៍ខ្មែរ" និងបានចេញលិខិតរួមគ្នាចុងក្រោយនេះ សម្រាប់អង្គការសង្គមស៊ីវិលនៅទូទាំងពិភពលោក ដោយពន្យល់អំពីមូលហេតុដែលថាការមិនទទួលស្គាល់ការបោះឆ្នោត គឺជាមធ្យោបាយដែលមានតែមួយគត់ សម្រាប់ចំណាត់ការដែលសមស្រប។

យើងខ្ញុំសូមផ្ដល់ជូននូវព័ត៌មានថ្មី អំពីថាតើការបោះឆ្នោត ដូចដែលអង្គការសហប្រជាជាតិបានកំណត់រួចទៅហើយនោះ ថាជាការបោះឆ្នោត ដែលមិនអាចចាត់ទុកថាមានភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌ ឬស្របច្បាប់នោះឡើយ ដោយសារតែលោក ហ៊ុន សែន បានបើកយុទ្ធនាការទ្រង់ទ្រាយធំ និងពេញទំហឹងក្នុងការបង្ក្រាបយ៉ាងចាស់ដៃ ជាពិសេសដោយពិចារណាទៅលើចំណុចដូចខាងក្រោម៖

១) របាយការណ៍ថ្មីៗ ជាដំណាក់កាល និងសេចក្ដីថ្លែងការណ៍ ដោយទីភ្នាក់ងារកម្រិតខ្ពស់ និងមន្ត្រី (រួមទាំងឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ) របស់ស្ថាប័នអង្គការសហប្រជាជាតិ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដែលរកឃើញថា ការបោះឆ្នោតដោយមានភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងស្របច្បាប់នៅកម្ពុជា គឺមិនអាចកើតមានទៅរួចនោះឡើយ ដោយសារតែរដ្ឋាភិបាលលោក ហ៊ុន សែន បើកយុទ្ធនាការយូរអង្វែង និងពេញទំហឹង ក្នុងការបង្ក្រាប ដើម្បីបំបាត់គណបក្សប្រឆាំងដ៏មានឥទ្ធិពល និងបំផ្លាញការសម្ដែងមតិដោយសេរី និងសេរីភាពក្នុងការបំពេញការងារដោយឯករាជ្យរបស់អង្គការសង្គមស៊ីវិល។

២) លទ្ធផលនៃការត្រួតពិនិត្យនៅមូលដ្ឋាន និងកិច្ចខិតខំប្រឹងប្រែងរាយការណ៍ពីសហគមន៍ខ្មែរ បានបង្ហាញឲ្យឃើញ និងចងក្រងជាឯកសារ អំពីការណ៍ដែលរដ្ឋាភិបាលោក ហ៊ុន សែន បដិសេធលែងឲ្យមានជំហានវិជ្ជមាន និងមានន័យ ក្នុងការអនុវត្ត "ផែនការសកម្មភាពនៃវិធានការកែទម្រង់" ដូចដែលបានស្នើឡើងដោយអង្គការសហប្រជាជាតិ ដើម្បីធ្វើឲ្យដំណើរការនយោបាយប្រព្រឹត្តទៅដោយមានភាពសេរី និងយុត្តិធម៌ជាងនេះ និង

៣)ការពិតដ៏គួរឲ្យសោកសៅមួយ គឺថាលោក ហ៊ុន សែន បាន"បន្តសកម្មភាព"បង្ក្រាបយ៉ាងបំពានរបស់គាត់ ដើម្បីធ្វើយ៉ាងណាឲ្យការបោះឆ្នោតលើកនេះប្រព្រឹត្តទៅដោយគ្មានគូប្រកួតប្រជែង និងបន្តក្រាញអំណាចគ្មានទីបញ្ចប់របស់គាត់ ដោយគាត់ប្រព្រឹត្តមិនត្រឹមត្រូវ មានជាអាទិ៍ រំលាយគណបក្សសង្គ្រោះជាតិចោល កាលពីឆ្នាំ ២០១៧ កាត់ទោសប្រធានគណបក្សប្រឆាំងលោក កឹម សុខា កាលពីខែមីនា ឆ្នាំ ២០២៣ ឲ្យគាត់ជាប់ពន្ធនាគារ ២៧ឆ្នាំ ពីបទក្បត់ជាតិ បន្ត"ការជំនុំជម្រះក្ដីករណីព្រហ្មទណ្ឌជាទ្រង់ទ្រាយធំ" និងការចាប់មេដឹកនាំបក្សប្រឆាំង អ្នកហ៊ានរិះគន់រដ្ឋាភិបាល អ្នកកាសែតឯករាជ្យដាក់គុកតាមទំនើងចិត្ត និងការផាត់ចោលគណបក្សភ្លើងទៀននាពេលថ្មីៗនេះ ដែលគណបក្សនេះជាគណបក្សប្រឆាំង និងដៃគូប្រកួតប្រជែងដ៏គួរឲ្យជឿទុកចិត្តតែមួយគត់ គឺមិនឲ្យគណបក្សនេះចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនាពេលខាងមុខ។

អាស្រ័យហេតុនេះ សហគមន៍ខ្មែរសូម៖

១) ប្រកាសចាត់ទុកការបោះឆ្នោតជាតិ នាខែ កក្កដា ថាគ្មានសុពលភាព។
២) អំពាវនាវឲ្យរដ្ឋាភិបាលបរទេស និងសហគមន៍អន្តរជាតិ កុំទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតឆ្នាំ ២០២៣ និងកុំផ្តល់ភាពស្របច្បាប់ដល់រដ្ឋាភិបាលណាមួយ ដែលកើតចេញពីការបោះឆ្នោតក្លែងក្លាយ និងមិនស្របច្បាប់ ដូចដែលអង្គការសហប្រជាជាតិបានបញ្ជាក់ស្រាប់។
៣) អំពាវនាវឲ្យរដ្ឋាភិបាលបរទេស និងសហគមន៍អន្តរជាតិ ដាក់ទណ្ឌកម្មផ្នែកពាណិជ្ជកម្ម រហូតដល់មានការកែទម្រង់ប្រកបដោយអត្ថន័យ កើតមានឡើង ដែលអាចនាំឲ្យមានការរៀបចំការបោះឆ្នោតមួយ ដែលប្រព្រឹត្តទៅដោយមានភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌។
៤) អំពាវនាវឲ្យសហគមន៍ខ្មែរ និងអ្នកតស៊ូមតិដើម្បីសិទ្ធិមនុស្សឯទៀត ប្រកាន់យក“ការតាំងចិត្តតស៊ូមតិរបស់សហគមន៍ខ្មែរ” ដើម្បីប្ដេជ្ញាក្នុងការប្រើប្រាស់គ្រប់ទម្រង់ និងវេទិកាដែលអាចមាន នៅកម្រិតអន្តរជាតិ ដើម្បីតតាំងនឹងយុទ្ធនាការរំលោភបំពានសិទ្ធិមនុស្ស និងនីតិរដ្ឋរបស់រដ្ឋាភិបាលលោក ហ៊ុន សែន។
៥) អំពាវនាវឲ្យសហគមន៍ខ្មែរ រដ្ឋជាសមាជិក និងអ្នកតស៊ូមតិដើម្បីសិទ្ធិមនុស្សឯទៀត ថ្កោលទោសឲ្យបានខ្លាំងក្លា និងដាក់រដ្ឋាភិបាលកម្ពុជាឲ្យទទួលខុសត្រូវ ចំពោះការរំលោភបំពានអំណាចដែលមិនអាចទទួលយកបានទាំងនោះ ដោយចាប់ផ្តើមពីវគ្គត្រួតពិនិត្យជាសកលតាមកាលកំណត់លើកម្ពុជា ដែលគ្រោងធ្វើនៅខែ មេសា ឆ្នាំ ២០២៤ ដែលត្រូវរៀបចំដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។

យើងខ្ញុំសូមស្នើឲ្យសហគមន៍អន្តរជាតិ ចាត់វិធានការដូចខាងលើ ដើម្បីដាក់សម្ពាធអន្តរជាតិលើរបបលោក ហ៊ុន សែន រហូតដល់មានដំណើរប្រែប្រួលសមស្រប និងអនុលោមតាមអនុសាសន៍នៃវិធានការកែទម្រង់របស់អង្គការសហប្រជាជាតិ និងស្តារសិទ្ធិមនុស្ស ប្រជាធិបតេយ្យ នីតិរដ្ឋឡើងវិញ ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរទទួលបានតំណាងពិតប្រាកដ និងស្របច្បាប់របស់គាត់ឡើងវិញ។